ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ០៨ លេខ ០៣

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

# សកម្មភាព ការងារ

ECOSOCC

ក
ស
វ



Work Activities

ប្រចាំខែមីនា ឆ្នាំ២០១៥



# មាតិកាអត្ថបទ

## កិច្ចប្រជុំជំនាញបច្ចេកទេស រវាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល


| ល.រ | ឈ្មោះអត្ថបទ | លេខទំព័រ |
|---|---|---|
| ១- | សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការទទួលបន្ទុកការងារព្យាបាល និងស្តារនីតិសម្បទា អ្នកញៀនគ្រឿងញៀន | ១ |
| ២- | សេចក្តីព្រាងរបាយការណ៍ស្តីពីការត្រួតពិនិត្យឡើងវិញនៃការអនុវត្តអនុសញ្ញាសហប្រជាជាតិប្រឆាំងអំពើពុករលួយ (UNCAC) នៅកម្ពុជា | ៣ |
| ៣- | កិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ | ៦ |
| ៤- | ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជាប្រចាំខែកុម្ភៈ ឆ្នាំ២០១៥ | ៧ |
| ៥- | សកម្មភាពដទៃទៀតរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ១៥ |

## សេចក្តីព្រាងអនុក្រឹត្យស្តីពី

# ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការ ទទួលបន្ទុកការងារព្យាបាល និង ស្តារនីតិសម្បទា អ្នកញៀនគ្រឿងញៀន

កាលពីថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៥ នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ឆយ អូន** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ECOSOCC) និង ឯកឧត្តម **សុត គឹមសាន** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ **សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការទទួលបន្ទុកការងារព្យាបាល និងស្តារនីតិសម្បទា អ្នកញៀនគ្រឿងញៀន** ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិកនិងមន្ត្រីនៃក.ស.វ. សមាជិកនិងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។



អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនបានរៀបចំសេចក្តីព្រៀងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការទទួលបន្ទុកការងារព្យាបាល និងស្តារនីតិសម្បទា អ្នកញៀនគ្រឿងញៀន ដើម្បីធ្វើជាសេនាធិការជូនអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្នុងការដឹកនាំលើការផ្តល់សេវាព្យាបាល បង្ការ ថែទាំ និងកាត់បន្ថយគ្រោះថ្នាក់ដែលបណ្តាលមកពីការប្រើប្រាស់គ្រឿងញៀន ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ និងសមាហរណកម្មជនដែលបានរងគ្រោះដោយសារគ្រឿងញៀនទៅក្នុងសង្គមវិញ។ សេចក្តីព្រាងនេះ ត្រូវបានរៀបចំឡើងដោយចែកចេញជា ៦ ជំពូក និង ១១ មាត្រា។ សមាសភាពរបស់គណៈកម្មាធិការទទួលបន្ទុកការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ដឹកនាំដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាល និងមានសមាជិកមកពីក្រសួង ស្ថាប័នពាក់ព័ន្ធមួយចំនួន និងមានតួនាទី ភារកិច្ច ដែលប្រគល់ដោយអាជ្ញាធរជាតិ ប្រយុទ្ធប្រឆាំងគ្រឿងញៀន និងរាជរដ្ឋាភិបាល ដើម្បីសម្រេចគោលបំណងឲ្យបានប្រសិទ្ធភាពខ្ពស់។



អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីព្រាងឯកសារនេះ ហើយបានសម្រេចកែសម្រួល ទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងទៀត ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ[១]។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងនេះទាំងស្រុង។



(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការទទួលបន្ទុកការងារព្យាបាល និងស្តារនីតិសម្បទា អ្នកញៀនគ្រឿងញៀន។

## សេចក្តីព្រាងរបាយការណ៍ស្តីពី

# ការត្រួតពិនិត្យឡើងវិញនៃការអនុវត្តអនុសញ្ញាសហប្រជាជាតិប្រឆាំងអំពើពុករលួយ (UNCAC) នៅកម្ពុជា

កាលពីថ្ងៃទី១៨ និងថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៥ នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ហុខ ថា** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **អ៊ុំ ម៉ុនធឿន** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ**សេចក្តីព្រាងរបាយការណ៍ស្តីពីការត្រួតពិនិត្យឡើងវិញនៃការអនុវត្តអនុសញ្ញាសហប្រជាជាតិប្រឆាំងអំពើពុករលួយ (UNCAC) នៅកម្ពុជា** ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិកនិងមន្ត្រីនៃក.ស.វ. សមាជិកនិងមន្ត្រី នៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងអង្គភាពប្រឆាំងអំពើពុករលួយ។



អនុសញ្ញាសហប្រជាជាតិស្តីពីការប្រឆាំងអំពើពុករលួយ (United Nation Convention Against Corruption-UNCAC) ជាលិខិតបទដ្ឋានគតិយុត្តអន្តរជាតិដែលមានសារសំខាន់ក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយកម្រិតសកលលោក។ UNCAC ត្រូវបានអនុម័ត ដោយមហាសន្និបាតអង្គការសហប្រជាជាតិ កាលពីថ្ងៃទី៣១ ខែតុលា ឆ្នាំ២០០៣ ហើយបានចូលជាធរមាននៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៥ ដែលរហូតមកដល់ពេលនេះមានរដ្ឋជាសមាជិកចំនួន ១៧២ ហើយប្រទេសកម្ពុជាបានចូលជាសមាជិកនៃ UNCAC កាលពីថ្ងៃទី៥ ខែតុលា ឆ្នាំ២០០៧។ ដើម្បីធានាបាននូវការគោរព UNCAC សម្រាប់រដ្ឋជាសមាជិកចូលរួម និងអនុវត្តតាម ដើម្បី (១). បំពេញកាតព្វកិច្ចអន្តរជាតិនៃរដ្ឋភាគីក្នុងការអនុវត្តអនុសញ្ញា (២). ផ្តល់កិច្ចសន្ទនាថ្នាក់ជាតិ និងការចូលរួមនៃភាគីពាក់ព័ន្ធដែលជួយដល់ការប្រឆាំងអំពើពុករលួយ (៣). ជួយបង្កើតកិច្ចសហប្រតិបត្តិការរវាងស្ថាប័ននានាក្នុងប្រទេសក្នុងការប្រឆាំងអំពើពុករលួយ (៤). ផ្តល់ព័ត៌មានលម្អិតដល់អ្នកកសាងគោលនយោបាយ (៥). ផ្តល់នូវទិដ្ឋភាពតម្រូវការជំនួយបច្ចេកទេស និង(៦). ចែករំលែកនូវចំណេះដឹងនិងបទពិសោធន៍។

យន្តការនៃការត្រួតពិនិត្យឡើងវិញនេះ ត្រូវបានចាប់ផ្តើមនៅឆ្នាំ២០១០ ហើយចែកជា ២ ជុំ ដោយក្នុង ១ជុំៗ មានរយៈពេល ០៥ឆ្នាំ។ ក្នុងជុំទី១ (២០១០-២០១៥) ត្រូវត្រួតពិនិត្យលើជំពូកទី៣ (ការដាក់ឧក្រិដ្ឋនិងការអនុវត្តច្បាប់) និងជំពូកទី៤ (កិច្ចសហប្រតិបត្តិការអន្តរជាតិ) រីឯជុំទី២ (២០១៥-២០២០) ត្រូវត្រួតពិនិត្យលើជំពូកទី២ (វិធានការទប់ស្កាត់) និងជំពូកទី៥ (ការរឹបអូសទ្រព្យសម្បត្តិមកវិញ)។ យន្តការនេះនិយាយដោយសាមញ្ញ គឺប្រទេសជារដ្ឋសមាជិក ត្រូវធ្វើការវាយតម្លៃការអនុវត្ត UNCAC របស់រដ្ឋសមាជិកផ្សេងទៀត ជាពិសេសអំពីច្បាប់នានាទាក់ទងនឹងការប្រឆាំងអំពើពុករលួយ អំពីការអនុវត្តក្នុងស្រុក និងអំពីវិធានការចាំបាច់នានាទាក់ទងនឹងការប្រឆាំងអំពើពុករលួយ។ ប្រទេសកម្ពុជាត្រូវបានជ្រើសរើសឲ្យត្រួតពិនិត្យប្រទេសម៉ាល់តា (២០១៣-២០១៤) ប្រទេសប៉ាឡៅ (២០១៤-២០១៥) និងប្រទេសអារ៉ាប៊ីសាអូឌីត (២០១៥) ហើយកម្ពុជាក៏ត្រូវបើកទ្វារទទួលអ្នកជំនាញប្រទេស មីយ៉ាន់ម៉ា និងតូហ្គោ អមដោយអ្នកជំនាញ អ.ស.ប. ឲ្យមានត្រួតពិនិត្យខ្លួន(២០១៥) ដែរ។ លក្ខណៈនៃការត្រួតពិនិត្យនេះគឺ (១). មិនមានលក្ខណៈឲ្យប្រទេសភាគីមានការប្រឈមគ្នាទេ (២). មិនមានលក្ខណៈប្រៀបធៀប ដាក់ទណ្ឌកម្ម ឬចាត់ចំណាត់ថ្នាក់ទេ និង(៣). សំដៅធ្វើយ៉ាងណាឲ្យមានកិច្ចសហប្រតិបត្តិការរវាងគ្នានឹងគ្នា តាមរយៈការចែករំលែកនូវការអនុវត្ត និងបទពិសោធល្អៗលើការដោះស្រាយចំពោះបញ្ហាប្រឈម ដោយមិនជ្រៀតជ្រែកលើកិច្ចការផ្ទៃក្នុងប្រទេសជាសមាជិកទេ[១]។

អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីព្រាងឯកសារនេះ ហើយបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងទៀត ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងនេះទាំងស្រុង។

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងរបាយការណ៍ស្តីពីការត្រួតពិនិត្យឡើងវិញនៃការអនុវត្តអនុសញ្ញាសហប្រជាជាតិប្រឆាំងអំពើពុករលួយ (UNCAC) នៅកម្ពុជា ។

# កិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ

កាលពីថ្ងៃព្រហស្បតិ៍ ទី១២ ខែមីនា ឆ្នាំ២០១៥ នៅវេលាម៉ោង ០៩:០០នាទីព្រឹក នៅទីស្តីការ គណៈរដ្ឋមន្ត្រី បានបើកអង្គប្រជុំត្រួតពិនិត្យចុងក្រោយ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដោយមានការអញ្ជើញចូលរួមពី ឯកឧត្តម **ឃឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ចសង្គមកិច្ច និងវប្បធម៌(ECOSOCC) អនុប្រធាន និងសមាជិក ECOSOCC ឯកឧត្តម **សយ សុខា** អគ្គលេខាធិការរាជរដ្ឋាភិបាល ក្រុមប្រឹក្សាអ្នកច្បាប់ ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** ក្រសួងសាមីនិងតំណាងក្រសួងពាក់ពន្ធ័ ដើម្បីពិនិត្យពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖

១- សេចក្តីព្រាងអនុក្រឹត្យ ស្តីពីនគរូបនីយកម្មរាជធានី ក្រុង និងទីប្រជុំជន។

២- សេចក្តីព្រាងព្រះរាជក្រឹត្យ ស្តីពីអនុវត្តការវាយតម្លៃលើផលប៉ះពាល់ នៃលិខិតបទដ្ឋាន គតិយុត្ត។

៣- បញ្ហាផ្សេងៗ។

ក្រោយពីបានពិនិត្យពិភាក្សាផ្លាស់ប្តូរយោបល់គ្នា អង្គប្រជុំបានសម្រេចនិងឯកភាពធ្វើការកែសម្រួលដូចតទៅ៖

១- សេចក្តីព្រាងអនុក្រឹត្យ ស្តីពីនគរូបនីយកម្មរាជធានី ក្រុង និងទីប្រជុំជន៖



**មូលបទ**

-ថែមចំណុចត្រេទី៩ "បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៣១៤/៣៧៣ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលមាត្រា២និងមាត្រា៥ នៃព្រះរាជក្រឹត្យលេខនស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ" ។

-ថែមមាត្រា២៧ថ្មី: លក្ខខណ្ឌបរិស្ថាននៃការការងារនគរូបនីយកម្ម និងសំណង់ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងរដ្ឋមន្ត្រីក្រសួងបរិស្ថាន។

- មាត្រា៤៧(ចាស់) ៤៨ថ្មី: បន្ថែមឃ្លា "និងបរិស្ថានល្អស្អាត នៅបន្ទាប់ពីពាក្យ លំហសាធារណៈ" ។

-ជំពូកទី៩ មានពីរមាត្រា យកទៅដាក់នៅក្នុង "ជំពូកទី១១ថ្មី បទប្បញ្ញត្តិដោយឡែក នៅខាងលើជំពូកទី១២ អន្តរប្បញ្ញត្តិ" វិញ។

-មាត្រា៦៤: អង្គប្រជុំបានពិភាក្សាគ្នាយ៉ាងផុលផុសនិងអស់រយៈពេលយ៉ាងយូររវាងក្រសួងសាមី និងស្ថាប័នមួយចំនួន ដូច្នេះក្រសួងសាមីសម្រេចលប់នៅត្រេទី៥និងទី៨ចេញ។

-សទ្ទានុក្រម: ពាក្យ អ្នកអភិវឌ្ឍអចលនវត្ថុ "**កែសម្រួលទៅជា ម្ចាស់សំណង់ ឬអ្នកអភិវឌ្ឍអចលនវត្ថុសំដៅដល់រូបវន្ត ឬនីតិបុគ្គល ដែលទទួលបានលិខិតអនុញ្ញាពីអាជ្ញាធរមានសមត្ថកិច្ច**" ។

២- សេចក្តីព្រាងព្រះរាជក្រឹត្យ ស្តីពីអនុវត្តការវាយតម្លៃលើផលប៉ះពាល់ នៃលិខិតបទដ្ឋានគតិយុត្តៈ

ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រធានអង្គប្រជុំ មានប្រសាសន៍ថា ការអនុវត្តការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត( RIA ) មានអត្ថប្រយោជន៍ណាស់ក្នុងការកែលម្អរាល់លិខិតបទដ្ឋានគតិយុត្តផ្សេងៗរបស់ក្រសួងស្ថាប័នឲ្យកាន់តែមានលក្ខណៈល្អប្រសើរឡើង។ ប៉ុន្តែការងារនេះជាការងារថ្មីមួយ ត្រូវរៀបចំឲ្យក្រសួងស្ថាប័នយល់ដឹងជ្រួលជ្រាបអំពីការអនុវត្តការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តនេះ ដូច្នេះឯកឧត្តមប្រធានអង្គប្រជុំបានណែនាំជូន ឯកឧត្តម **ឃឹម ណុលសន** នាយកគម្រោង RIA ត្រៀមឧទ្ទេសនាមដោយលើកយកករណីមួយចំនួនដែលច្បាស់លាស់ជាងគេជូនអង្គប្រជុំលើកក្រោយ។

អង្គប្រជុំត្រួតពិនិត្យចុងក្រោយបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងនេះ នៅវេលាម៉ោង ១២:៤៥នាទីក្រោមបរិយាកាសរីករាយ និងស្និទ្ធស្នាលបំផុត។



# ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំខែកុម្ភៈ ឆ្នាំ២០១៥*



របាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា**ប្រចាំខែកុម្ភៈ ឆ្នាំ២០១៤**នេះ ជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដឹកនាំដោយ ឯកឧត្តម **យឹម ឈុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការអញ្ជើញចូលរួមពី អនុប្រធាន សមាជិក សមាជិកា អគ្គលេខាធិការ អគ្គលេខាធិការរង ក.ស.វ. និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ។

## ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្តូរប្រាក់

➡ នាខែកុម្ភៈឆ្នាំ២០១៥សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់កើនឡើង១,២%ធៀបនឹងខែមុននិងកើនឡើង១,៦%ធៀបនឹងខែដូចគ្នាឆ្នាំមុន (រយៈពេល១២ខែ)។

តារាង១.១. បម្រែបម្រួលថ្លៃធៀបនឹងខែដូចគ្នាឆ្នាំមុនសម្រាប់ក្រុមទំនិញនិងមុខទំនិញមួយចំនួន

| ក្រុមទំនិញ: | | មុខទំនិញ: | |
|---|---|---|---|
| ម្ហូបអាហារ: | +៥% | បន្លែ: | +៧,៩% |
| សំលៀកបំពាក់ និងស្បែកជើង | +៣,៨% | សាច់ជ្រូក: | +៧,៨% |
| ភោជនីយដ្ឋាន: | +៣,៧% | ត្រីស្រស់: | +៧,២% |
| ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់ | +៣,៣% | ផ្លែឈើ: | +៧,១% |
| ការកំសាន្ត និងវប្បធម៌: | +២,៨% | សាច់គោ: | +៤,៤% |

តារាង១.២. បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ២០១៣–២០១៥

| ឆ្នាំ | ធៀបនឹងខែ | មករា | កុម្ភៈ | មីនា^P | មេសា^P | ឧសភា^P | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១៥ | ដូចគ្នាឆ្នាំមុន | ០,៤% | ១,៦% | ១,៨% | ២,៣% | ៣,០% | | | | | | | | |
| | មុន | -០,៤% | ១,២% | ០,៧% | ១,០% | ១,០% | | | | | | | | |
| ២០១៤ | ដូចគ្នាឆ្នាំមុន | ៤,៥% | ៤,៣% | ៥,០% | ៤,៩% | ៤,៦% | ៤,៩% | ៤,២% | ៤,១% | ៣,៦% | ២,៩% | ២,៤% | ២,៥% | ៤,០% |
| | មុន | ០,២% | ០ | ០,៥% | ០,៥% | ០,៣% | ០,៥% | ០,៤% | ០,៣% | ០,២% | -០,៤% | -០,៨% | ០,៧% | |
| ២០១៣ | ដូចគ្នាឆ្នាំមុន | ១,៨% | ១,៧% | ១,០% | ១,០% | ២,៨% | ២,៩% | ៤,០% | ៣,៣% | ៣,៩% | ៤,២% | ៤,១% | ៤,៧% | ៣,០% |
| | មុន | ០,៣% | ០,២% | -០,១% | ០,៦% | ០,៧% | ០,២% | ១% | ០,៤% | ០,៧% | ០,២% | -០,៣% | ០,៥% | |

**P:** តួលេខខែមិនា មេសា និងឧសភាឆ្នាំ២០១៥ ជាតួលេខព្យាករ (តាមវិធីសាស្ត្រ **DECOMPOSITION**)

* ការវិភាគជាសំណេរដកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្របដណ្តប់តួលេខទាំងអស់ទេ (មើលតារាងភ្ជាប់មកជាមួយ)។

* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរ និងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទ តាងឲ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ (Excel) សញ្ញាក្បៀសតាងឲ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

ក្រាហ្វ ១.១. ចលនានិងបម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់




តារាង១.៣. អត្រាប្តូរប្រាក់

| ប្រភេទ | កុម្ភៈ២០១៥ | មករា២០១៥ | កុម្ភៈ២០១៤ | ប្រភេទ | កុម្ភៈ២០១៥ | មករា២០១៥ | កុម្ភៈ២០១៤ |
|---|---|---|---|---|---|---|---|
| **៛/ដុល្លារ** | ៤០២៧៛/១$ | ៤០៦០៛/១$ | ៣៩៨០៛/១$ | **បាត/ដុល្លារ** | ៣២,៣៧បាត/១$ | ៣២,៧៦បាត/១$ | ៣២,៥៧បាត/១$ |
| **៛/បាត** | ១២៤៛/១បាត | ១២៤៛/១បាត | ១២២៛/១បាត | **ដុង/ដុល្លារ** | ២១៣៣៥ដុង/១$ | ២១៣២០ដុង/១$ | ២១០៨០ដុង/១$ |
| **៛/ដុង** | ០,១៨៩៛/១ដុង | ០,១៩០៛/១ដុង | ០,១៨៩៛/១ដុង | | | | |

## ២) ស្ថានភាពថវិកាជាតិ

➡យោងតាមស្ថិតិរបស់រតនាគារជាតិអគ្គនាយកដ្ឋានគយនិងរដ្ឋាករ និងអគ្គនាយកដ្ឋានពន្ធដារក្នុងខែកុម្ភៈឆ្នាំ២០១៥ ថវិកាជាតិមានស្ថានភាពដូចខាងក្រោម៖



**២.១. ចំណូលថវិកាជាតិ**: អនុវត្តបាន៦៩៦,៦ពាន់លានរៀល( *មធ្យមប្រចាំខែ ៦៧% នៃផែនការ*) ក្នុងនោះ ចំណូលចរន្តចំនួន៦៩៥,៩ពាន់លានរៀល( *មធ្យមប្រចាំខែ ៦៦% នៃផែនការ*) និងចំណូលមូលធនមាន០,៧ពាន់លានរៀល( តាមតួលេខ រតនាគារជាតិ )។

➢បើធៀបនឹងខែមុនចំណូលថវិកាជាតិកើនឡើង ២០,២%ប៉ុន្តែថយចុះ៤%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢នៅក្នុងចំណូលចរន្ត:

✓ចំណូលសារពើពន្ធមានចំនួន ៦៧១,០ពាន់លានរៀល កើនឡើង២៤,៤% ធៀបនឹងខែមុនប៉ុន្តែថយចុះ០,១% ធៀបនឹងខែដូចគ្នាឆ្នាំមុន( តាមតួលេខ រតនាគារជាតិ )។

ក្រាហ្វ ២.១. ចំណូលថវិកាជាតិ ឆ្នាំ ២០១៣-២០១៥ (ពាន់លានរៀល)




✓ចំណូលមិនមែនសារពើពន្ធមានចំនួន ២៤,៩ពាន់លានរៀល ថយចុះ៣៨,៣%ធៀបនឹងខែមុន និងថយចុះ៥៣,៣%ធៀបនឹងខែដូចគ្នាឆ្នាំមុន( តាមតួលេខ រតនាគារជាតិ )។

**តារាង២.១. មុខចំណូលមួយចំនួនក្នុងចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ**

| **ចំណូលសារពើពន្ធ** (ក្នុងរង្វង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | | **ចំណូលមិនមែនសារពើពន្ធ** (តាមតួលេខ រតនាគារជាតិ) (ក្នុងរង្វង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | |
|---|---|---|---|
| ➢ ពន្ធ និងអាករគយ:៦-% (អគ្គនាយកដ្ឋានគយ និងរដ្ឋាករ) | (+៩,៥%) | ➢ នេសាទ:-៨៣,២% | (-៨៧,៣%) |
| ➢ ចំណូលពន្ធដារ: -៤,៧% (អគ្គនាយកដ្ឋានពន្ធដារ) | (+២៣,៥%) | ➢រុក្ខាប្រមាញ់: | ( ) |
| ➢ ចំណូលសារពើពន្ធផ្សេងៗ:+១០១,៣% (តាមតួលេខ រតនាគារជាតិ) | (-២០%) | ➢សម្បទានរ៉ែ: -៩៥,៤% | (-៩៥,៦%) |
| ✧ កាស៊ីណូ :-៤,៥% | (-២៧,៦%) | ➢ អាកាសចរណ៍ស៊ីវិល:+១៦០៧,៨% | (+១១,២%) |
| ✧ អាជ្ញាបណ្ណក្នុងស្រុក : +១២៩០,១% | (-៥៧,៩%) | ➢ផលទុននៃសកម្មភាពទេសចរណ៍: +១៦៣% | (-៦៤,៤%) |
| ✧កម្រៃគ្រប់គ្រងនិងទិដ្ឋាការនាំចេញ : +៨០៨៣,៦% | (-៧,៤%) | ➢ប្រៃសណីយ៍ និងទូរគមនាគមន៍: -១៤,៥% | (-៥៨,៦%) |
| | | ➢អាករស្ថានទូត( លិខិតឆ្លងដែននិងទិដ្ឋាការ ): -៩១,២% | (-៩០%) |
| | | ➢ចំណូលផ្សេងៗទៀតពុំមែនសារពើពន្ធ: | |

**២.២. ចំណាយថវិកាជាតិ** :អនុវត្តបាន ៤៩២,៦ពាន់លានរៀល( *មធ្យមប្រចាំខែ ៣៨% នៃផែនការ*) ក្នុងនោះ ចំណាយចរន្ត ចំនួន ៣៨២,២ពាន់លានរៀល ( *មធ្យមប្រចាំខែ ៥០% នៃផែនការ*) និងចំណាយមូលធនមានចំនួន ១១០,៤ពាន់លានរៀល( តាមតួលេខ រតនាគារជាតិ )។

➤ចំណាយថវិកាជាតិកើនឡើង៨,៩%ធៀបនឹងខែមុនប៉ុន្តែថយចុះ៣០,១%ធៀបនឹងខែដូចគ្នាឆ្នាំមុន។ក្នុងនោះចំណាយចរន្តថយចុះ០,៣%ធៀបនឹងខែមុននិងថយចុះ៤១,៦%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

**២.៣. សមតុល្យថវិកាជាតិ** : ថវិកាជាតិនាខែនេះមានអតិរេកចំនួន **២០៣,៩ពាន់លានរៀល** (តាមតួលេខ រតនាគារជាតិ)។

ក្រាហ្វ២.២. ចំណាយថវិកាជាតិ ឆ្នាំ ២០១៣–២០១៥
(ពាន់លានរៀល)




## ៣) ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➡ស្ថានភាពរូបិយវត្ថុ ក្នុងខែកុម្ភៈឆ្នាំ២០១៥មានលក្ខណៈដូចខាងក្រោម៖

➤រូបិយវត្ថុ$M_2$ មានចំនួន៤៣៣៦០ពាន់លានរៀលថយចុះ០,៣%ធៀបនឹងខែមុន ប៉ុន្តែកើនឡើង២៨% ធៀបនឹងខែដូចគ្នាឆ្នាំមុន។**ការថយចុះ$M_2$** ក្នុងខែនេះ ជារួម បណ្តាលមកពីការថយចុះនៃប្រាក់បញ្ញើចរន្ត៣% ប្រាក់បញ្ញើមានការកំណត់ និងសន្សំ០,១% និងប្រាក់បញ្ញើជារូបិយបណ្ណ០,៤%។

➤ក្នុងខែនេះ ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារមានចំនួន១៨% និងប្រាក់បញ្ញើជារូបិយបណ្ណមានចំនួន៨២% នៃរូបិយវត្ថុ$M_2$។

ក្រាហ្វ៣.១. សមាសធាតុរូបិយវត្ថុខែកុម្ភៈឆ្នាំ២០១៥




តារាង៣.១. សមាមាត្រចំនួនប្រាក់រៀល នៅក្នុងរូបិយវត្ថុ $M_2$ ឆ្នាំ២០១៥

| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារ | ១៧,៩% | ១៨% | | | | | | | | | | |
| ប្រាក់រៀលក្រៅធនាគារ | ១៣,៦% | ១៣,៧% | | | | | | | | | | |

ក្រាហ្វ៣.២.បម្រែបម្រួលសមាសធាតុរូបិយវត្ថុខែកុម្ភៈ២០១៥: ក្នុងវង់ក្រចកជាបម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន



➢**ទុនបម្រុងជារូបិយបណ្ណបរទេសសុទ្ធ**មានចំនួន ៤៣៤២លានដុល្លារ ថយចុះ០,៦%ធៀបនឹងខែមុន ប៉ុន្តែកើនឡើង១៩,៥% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢ ***ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិ*** ក្នុងខែនេះមានចំនួន ១២៧៦២ ពាន់លានរៀល ថយចុះ ០,៦% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង១៦%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៣.២.ការផ្តល់ឥណទាននិងអត្រាការប្រាក់ប្រចាំឆ្នាំ

| ផ្តល់ដោយ | កុម្ភៈ២០១៥ | មករា២០១៥ | កុម្ភៈ២០១៤ |
|---|---|---|---|
| ឥណទានផ្តល់ដោយធនាគារពាណិជ្ជ(ពាន់លានរៀល) ក្នុងនោះ ជារៀល | | ៣៩៤០៨ | ៣១៣៣១ |
| ឥណទានផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ(ពាន់លានរៀល) | | | ៥៧៧៧ |
| អត្រាការប្រាក់បញ្ញើជារៀលនៅធនាគារពាណិជ្ជ | | | ៥,៨៥% |
| អត្រាការប្រាក់កម្ចីជារៀលនៅធនាគារពាណិជ្ជ | | | ១៥,៩៣% |
| អត្រាការប្រាក់បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | | | ៤,២៧% |
| អត្រាការប្រាក់កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | | | ១១,១៧% |

## ៤) ស្ថានភាពកសិកម្ម ឧស្សាហកម្ម សេវាកម្ម និងវប្បធម៌

➡ក្នុងខែកុម្ភៈឆ្នាំ២០១៥ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម៖

➢**កសិកម្ម**:

✓នេសាទសម្រេចបាន៥៦,៥ពាន់តោន កើនឡើង៣%ធៀបនឹងខែមុន ប៉ុន្តែថយចុះ១៩%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢**រ៉ែ និងថាមពល**:

✓ អគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន៤០១,៦GWHមានការកើនឡើង៣%ធៀបនឹងខែមុន និងកើនឡើង២៥%ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះផ្គត់ផ្គង់ដោយវារីអគ្គិសនីមានចំនួន ៦៦,២ GWHមានការថយចុះ២៣%ធៀបនឹងខែមុន ប៉ុន្តែកើនឡើង១៣៦%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢**ឧស្សាហកម្ម**:

✓ផលិតកម្មវាយនភណ្ឌនិងស្បែកជើងមានចំនួន៤៧៨,៤លានដុល្លារមានការថយចុះ៤%ធៀបនឹងខែមុន ប៉ុន្តែកើនឡើង៨%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៤.១. ការចុះបញ្ជីរោងចក្រ និងឧស្សាហកម្មធុនតូច និងសិប្បកម្ម នៅក្រសួងឧស្សាហកម្ម

| ប្រភេទ | ចំនួន–កុម្ភៈ២០១៥ | ចំនួន–មករា២០១៥ | ចំនួន–កុម្ភៈ២០១៤ |
|---|---|---|---|
| ▪រោងចក្រថ្មីដែលបានចុះបញ្ជី | ៩ | ៥ | ២០ |
| ▪ ចំនួនរោងចក្រសរុបដែលមានក្នុងបញ្ជី | ១៣១៥ | ១៣០៦ | ១១១៣ |
| ▪ ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | | — | ៨ |
| ▪ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | | — | |

➢**សំណង់** (ការអនុញ្ញាត):

✓សំណង់អនុញ្ញាតឲ្យសាងសង់មានចំនួន ១៩២ពាន់ម$^2$កើនឡើង២៧%ធៀបនឹងខែមុនប៉ុន្តែថយចុះ៦៧% ធៀបនឹងខែដូចគ្នាឆ្នាំមុន។បើគិតជាសាច់ប្រាក់ស្មើនឹង៥២,៨លានដុល្លារកើនឡើង១៤%ធៀបនឹងខែមុន ប៉ុន្តែថយចុះ៦៩%បើធៀបនឹងខែដូចគ្នាឆ្នាំមុន។ក្នុងនោះប្រភេទសំណង់ចម្បងៗមាន៖

តារាង៤.២. សំណង់អនុញ្ញាតតាមប្រភេទផ្សេងៗ

| ប្រភេទ | ពាន់ម² —កុម្ភៈ២០១៥ | ពាន់ម² —មករា២០១៥ | ពាន់ម² —កុម្ភៈ២០១៤ |
|---|---|---|---|
| ▪ លំនៅឋាន | ៤៩,៧ | ៦២,៣ | ១៨៥,៦ |
| ▪ ឧស្សាហកម្ម | ១២៥,៧ | ៤៧,៤ | ២៩៣,៧ |
| ▪ទេសចរណ៍ | ៦,៧ | ២៧,២ | ២៣,៥ |
| ▪ពាណិជ្ជកម្ម | ៣,២ | ៣,៤ | ៥៨ |
| ▪ផ្សេងៗ | ៣,១ | ០,៧ | ២៦,៨ |
| អនុញ្ញាតសរុប | ១៩២ | ១៥១,០ | ៥៨៨,៣ |

✓ដូច្នេះសំណង់អនុញ្ញាតដែលពេញនិយមនាខែនេះគឺឧស្សាហកម្ម៦៥,៥% និង លំនៅដ្ឋាន២៥,៩%នៃផ្ទៃក្រឡាសរុប។

### ➢ការងារ:

តារាង៤.៣. ការស្វែងរកការងារនិងទទួលបានការងារ

| ប្រភេទ | នាក់—កុម្ភៈ២០១៥ | នាក់—មករា២០១៥ | នាក់—កុម្ភៈ២០១៤ |
|---|---|---|---|
| អ្នកចុះឈ្មោះស្វែងរកការងារ ( ទីភ្នាក់ងារជាតិមុខរបរ និងការងារ ) | ១០២២ | ៩៧៧ | ២៨ |
| អ្នកទទួលបានការងារតាមរយៈក្រសួងការងារ និងក្រុមហ៊ុន | ២៩៨៨ | ២៨៧០ | ៣០៤១ |
| អ្នកទទួលបានការងារក្នុងប្រទេស | ១៥៧៤ | ១៣១៩ | ២៥៣១ |
| អ្នកទទួលបានការងារក្រៅប្រទេស | ១៤១៤ | ១៥៥១ | ១១៥៣ |

### ➢វិនិយោគ

តារាង៤.៤.គម្រោងវិនិយោគអនុញ្ញាតដោយគ.វ.ក./ក.អ.ក. (ថ្មីនិងពង្រីក)

| ប្រភេទ | កុម្ភៈ២០១៥ | មករា២០១៥ | កុម្ភៈ២០១៤ |
|---|---|---|---|
| អនុញ្ញាតសរុប (លានដុល្លារ) | ៣៥,៧ | ៧៣,១ | ១០៩,៨ |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ០,០ | ០,០ | ២៣ |
| វិស័យឧស្សាហកម្ម (ក្នុងរង់ក្រចកជាតួលេខនៃតំបន់សេដ្ឋកិច្ចពិសេស) | ៣៥,៧<br>(៨,៩) | ៣៦.៩<br>(១០,៧) | ៥៣,២<br>(១៤) |
| វិស័យទេសចរណ៍ | ០,០ | ៣៣,៧ | ៣៣,៦ |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ០,០ | ២.៥ | ០,០ |
| ចំនួនគម្រោង ថ្មីនិងពង្រីក (ចំនួន) | ១២ | ១១ | ១៧ |
| បង្កើតការងារ (ពាន់នាក់) | ១៣,៤ | ១០,៧ | ១៧,១ |

### ➢សេវាកម្ម

តារាង៤.៥.ការចុះបញ្ជីនិងលុបចេញពីបញ្ជី នៅក្រសួងពាណិជ្ជកម្ម

| ប្រភេទ | ចំនួន —កុម្ភៈ២០១៥ | ចំនួន—មករា២០១៥ | ចំនួន—កុម្ភៈ២០១៤ |
|---|---|---|---|
| ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ៣៩៥ | ៤២៦ | ៣១៣ |
| ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ៥ | ៤ | ២ |
| ក្រុមហ៊ុនដែលបានចុះបញ្ជីបង់ពន្ធដារតាមរបបពិត | | ១២០ | ៤៩៥ |

➤ **ទំនិញឆ្លងកាត់កំពង់ផែ**(សរុប៥កំពង់ផែ) មានចំនួន៧៦៩,៥ពាន់តោនកើនឡើង៩%ធៀបនឹងខែមុន និង កើនឡើង១៣%ធៀបនឹងខែដូចគ្នាឆ្នាំមុនក្នុងនោះ:

តារាង៤.៦.ទំនិញឆ្លងកាត់កំពង់ផែផ្សេងៗ (ក្នុងវង់ក្រចក: បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន)

| | | | |
|---|---|---|---|
| ▪ កំពង់ផែភ្នំពេញ:+១៦% | (+៧៦%) | ▪ កំពង់ផែស្រែអំបិល និងកោះកុង:+៤០% | (-៣៨%) |
| ▪ កំពង់ផែកំពង់សោម:+៤% | (+៣៦%) | ▪ កំពង់ផែឧកញ៉ាម៉ុង: -៦% | (-៥១%) |

➤ **ការធ្វើដំណើរតាមផ្លូវអាកាសនិងទេសចរណ៍**

តារាង៤.៧.អ្នកដំណើរតាមផ្លូវអាកាសនិងទេសចរណ៍

| ប្រភេទ | ចំនួន(ពាន់នាក់) | %∆ ធៀបនឹងខែមុន | %∆ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ២២,៦ | ២១% | ៣២% |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | ៤៥,៦ | ២% | ៧៧% |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ៥៤២,៦ | –៦% | ៣% |
| ចំនួនទេសចរជាតិចេញក្រៅប្រទេស | | | |
| ចំនួនទេសចរអន្តរជាតិមកព្រះរាជាណាចក្រកម្ពុជា<br>✓ តាមផ្លូវអាកាស<br>✓ តាមផ្លូវគោក និងទឹក | | | |

## ៥) ស្ថានភាពពាណិជ្ជកម្ម

➡ ពីប្រភពអគ្គនាយកដ្ឋានគយនិងរដ្ឋាករ ការនាំចូលនាខែកុម្ភៈមានចំនួន ៤០៩២,២ពាន់លានរៀល (ស្មើនឹង ១០២៣លានដុល្លារ ស.រ.អា.)កើនឡើង១០,៤%ធៀបនឹងខែមុននិងកើនឡើង៥៧,៣%ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះ៖

តារាង៥.១.បម្រែបម្រួលនៃការនាំចូលមុខទំនិញមួយចំនួន

| ទំនិញ | %∆ធៀបនឹងខែមុន | %∆ធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %∆ធៀបនឹងខែមុន | %∆ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ប្រេងសាំង | +១៦,៧% | +១៦,៩% | រថយន្តសរុប (ព.ល.រ) | -៥,៦% | +១៨,៨% |
| ប្រេងម៉ាស៊ូត | -១២,៤% | +១៥,៨% | រថយន្តសរុប (គ្រឿង) | -៩,៨% | -១២,២% |
| ឧស្ម័ន | +១០,១% | +៦១,៣% | ត្រាក់ទ័រនិងគោយន្ត(គ្រឿង) | +១,២% | +១០% |
| អគ្គិសនីនាំចូល | +៧,១% | -២០,៣% | ម៉ូតូ (គ្រឿង) | | |
| ដែកសំណង់ | -៣៤,៦% | -២៨,៧% | អង្ករ | +៤៥,៩% | -៣៣,៤% |
| ស៊ីម៉ង់ត៍ | +៤,១% | -៤,៤% | ផ្លែឈើនិងបន្លែ | +៦,៩% | -៣០% |
| គ្រឿងអេឡិចត្រូនិក | | | ជីនិងថ្នាំកសិកម្ម | -២០,៣% | -៤៣,៦% |
| | | | នាំចូលក្នុងក្របខណ្ឌច្បាប់វិនិយោគ | +៥,៧% | +៦៨,៩% |

➡ **ការនាំចេញ** ខែកុម្ភៈឆ្នាំ២០១៥ មានចំនួន**២៦៣៥,៣**ពាន់លានរៀល ស្មើនឹង**៥៦៨**,៨លានដុល្លារ ស.រ.អា. (**៦៤**,៤% នៃការនាំចូល)ថយចុះ២៣,៧%ធៀបនឹងខែមុន ប៉ុន្តែកើនឡើង១,៧%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៥.២.បម្រែបម្រួលនៃការនាំចេញមុខទំនិញមួយចំនួន

| ទំនិញ | %ធៀបនឹងខែមុន | %ធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %ធៀបនឹងខែមុន | %ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ផលិតផលឈើកែឆ្នៃ | -៨៩,៦% | -៩៧,៣% | ផលិតផលនេសាទ | | |
| វាយនភណ្ឌនិងស្បែកជើង | -១៩,១% | -២,៥% | កៅស៊ូ | -៤៥,៩% | +១១៤,២% |
| អង្ករ | -៥,៧% | +៣០,៦% | | | |

➡ក្នុងខែកុម្ភៈនេះជញ្ជីងពាណិជ្ជកម្មមានឱនភាពចំនួន ១៤៥៦,៩៣ពាន់លានរៀលស្មើនឹង៣៦៤,២លានដុល្លារ ស.រ.អា.។

## ៦) បម្រែបម្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងខែកុម្ភៈឆ្នាំ២០១៥នេះ សូចនាករសេដ្ឋកិច្ច សង្គមកិច្ច នៃព្រះរាជាណាចក្រកម្ពុជាបង្ហាញបម្រែបម្រួលគួរឲ្យចាប់អារម្មណ៍ដូចក្នុងតារាងខាងក្រោម។

តារាង៦.១. បម្រែបម្រួលគួរឲ្យចាប់អារម្មណ៍ នៃសូចនាករមួយចំនួន

| ល.រ | សូចនាករ | ធៀបនឹងខែមុន | ធៀបនឹងខែដូចគ្នាឆ្នាំមុន | កំណត់សម្គាល់ |
|---|---|---|---|---|
| ១ | អាករលើផលរបរ | -១០.៤% | -១៤.៤% | — |
| | ចំណូលថវិកាជាតិ | +២០% | -៤% | — |
| ២ | សំណង់អនុញ្ញាតឲ្យសាងសង់ | +២៧% | -៦៧% | — |
| ៣ | ទុនវិនិយោគអនុញ្ញាតដោយក.អ.ក. | -៥១% | -៦៧% | — |
| ៤ | ការនាំចូល | +១០,៤% | +៥៧,៣% | ជាតួលេខដែលកត់ត្រាបានដោយ អគ្គនាយកដ្ឋានគយ និងរដ្ឋាករ។ ក្នុងខែកុម្ភៈនេះ មានចំនួន ៤០៩២,២ ពាន់លានរៀល។ |
| ៥ | ការនាំចេញផលិតផលវាយនភណ្ឌនិងស្បែកជើង | -១៩,១% | -២,៥% | — |

## ៧) សេចក្ដីសន្និដ្ឋាន

យោងតាមតួលេខរយៈពេល២ខែ ដើមឆ្នាំ២០១៥នេះ យើងសង្កេតឃើញស្ថានភាពទូទៅនៃសូចនាករមួយចំនួនរបស់សេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាដូចខាងក្រោម៖

១) ថ្លៃទំនិញមាននិន្នាការកើនឡើង បន្ទាប់ពីមានកម្រិតទាបក្នុងអំឡុងឆ្នាំ២០១៤។ ការឡើងថ្លៃនេះជារួមបណ្ដាលមកពីក្រុមម្ហូបអាហារ ។

២) ថ្លៃប្រេងនៅកម្ពុជាមានការកើនឡើងវិញបន្ទាប់ពីចុះថ្លៃមួយរយៈ ទោះបីជាថ្លៃប្រេងលើទីផ្សារអន្តរជាតិពុំមានការកើនឡើងក៏ដោយ។

៣) សកម្មភាពធុរកិច្ចដូចជា ក្នុងវិស័យសំណង់ និងវិនិយោគ មានកំណើនទាប ចំនួនរោងចក្រសហគ្រាសបើកថ្មីមានកម្រិតទាប ផលិតកម្មនិងការនាំចេញផលិតផលវាយនភណ្ឌនិងស្បែកជើងធ្លាក់ចុះជាហេតុនាំឲ្យមានផលប៉ះពាល់ដល់ចំណូលថវិកាជាតិ ដោយក្នុងរយៈពេល២ខែដើមឆ្នាំនេះការអនុវត្តចំណូលថវិកាមានកម្រិតទាបធៀបនឹងផែនការ។ ពិធីបុណ្យចូលឆ្នាំចិន-វៀតណាមអាចជាកត្តាជះឥទ្ធិពលលើការថយចុះនេះ។

ជារួម យើងសង្ឃឹមថា សេដ្ឋកិច្ច សង្គមកិច្ចកម្ពុជានឹងមានលទ្ធផលល្អប្រសើរសម្រាប់ឆ្នាំ២០១៥ទាំងមូល។

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមីនា ឆ្នាំ២០១៥

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០២/០៣/១៥<br>ម៉ោង០៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីប្រកាសបើកយុទ្ធនាការអក្ខរកម្មជាតិឆ្នាំ២០១៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិ ព្រឹទ្ធបណ្ឌិត នៅវិទ្យាស្ថានជាតិអប់រំ។ |
| ២ | ០៤/០៣/១៥<br>ម៉ោង០៩:០០នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥។<br>២-សេចក្តីព្រាងអនុក្រឹត្យ ស្តីពីនីតិវិធីនៃការបង្កើត ការរំលាយចោល និងការកំណត់តួនាទី និងភារ កិច្ចនៃសហគមន៍កសិករប្រើប្រាស់ទឹក។<br>៣-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៣ | ០៤/០៣/១៥<br>ម៉ោង១៥:៣០នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មការតាមដាន និងត្រួតពិនិត្យលើការសាងសង់អាកាសយានដ្ឋានអន្តរជាតិ ដើម្បីពិនិត្យលើប្លង់ពង្រីកអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៤ | ០៥/០៣/១៥<br>ម៉ោង០៨:៣០នាទី | ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីប្រជុំស្តីពីការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមករា ឆ្នាំ២០១៥ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៥ | ០៦/០៣/១៥<br>ម៉ោង០៨:៣០នាទី | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្តីព្រាងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥។<br>២-សេចក្តីព្រាងអនុក្រឹត្យ ស្តីពីនីតិវិធីនៃការបង្កើត ការរំលាយចោល និងការកំណត់តួនាទី និងភារ កិច្ចនៃសហគមន៍កសិករប្រើប្រាស់ទឹក។<br>៣-បញ្ហាផ្សេងៗ។<br>នៅទីស្តីការនាយករដ្ឋមន្ត្រី។ |

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមីនា ឆ្នាំ២០១៥ (ត)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ៦ | ០៨/០៣/១៥<br>**ម៉ោង០៨:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីអបអរសាទរទិវាខួបលើកទី១០៤ ទិវាអន្តរជាតិនារី ៨មីនា ២០១៥ ក្រោម ប្រធានបទ “ដំណើរឆ្ពោះទៅមុខ៖ ស្ត្រីកម្ពុជាក្រោយសន្និសីទស្ត្រីពិភពលោកឆ្នាំ១៩៩៥” ក្រោមអធិបតី ភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ៧ | ១០/០៣/១៥<br>**ម៉ោង០៧:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់វិញ្ញាបនបត្រជូនដល់កម្មសិក្សាការីមន្ត្រីជាន់ខ្ពស់ មន្ត្រីមធ្យមឆ្នាំ២០១៤ សិក្ខាកាមមន្ត្រីមធ្យមនៃក្រសួងបរិស្ថាន និងបើកវគ្គបណ្តុះបណ្តាលឆ្នាំ២០១៥ របស់សាលាភូមិន្ទរដ្ឋបាល ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត នៅវិទ្យាស្ថានជាតិអប់រំ។ |
| ៨ | ១០/០៣/១៥<br>**ម៉ោង១៤:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីបិទសន្និបាតបូកសរុបការងារសុខាភិបាលលើកទី៣៦ ឆ្នាំ២០១៤ និងលើកទិស ដៅការងារសម្រាប់ឆ្នាំខាងមុខ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត នៅសណ្ឋាគារសូហ្វីតែលភ្នំពេញ។ |
| ៩ | ១០/០៣/១៥<br>**ម៉ោង១៨:០០នាទី** | ចូលរួមជាកិត្តិយស ក្នុងឱកាសប្រារព្ធពិធីសម្ពោធហាង Maison Bienvenue នៅហាង Maison Bienvenue ភ្នំពេញ។ |
| ១០ | ១១/០៣/១៥<br>**ម៉ោង០៩:០០នាទី** | ដឹកនាំកិច្ចប្រជុំគណៈកម្មការបច្ចេកទេស ដើម្បីសម្របសម្រួល និងសហការជាមួយភាគីចិន ជាមួយនឹង ក្រុមហ៊ុនសាងសង់ហ្វាងគុង ដើម្បីពិភាក្សាលើសម្ភារៈតុបតែង និងសម្ភារៈអគ្គិសនី នៃគម្រោងសាងសង់ អគារមជ្ឈមណ្ឌលព័ត៌មាន និងបច្ចេកវិទ្យានៃទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១១ | ១១/០៣/១៥<br>**ម៉ោង១៥:០០នាទី** | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីអនុវត្តការវាយតម្លៃលើផលប៉ះពាល់ នៃលិខិតបទដ្ឋានគតិយុត្ត។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីនគរូបនីយកម្មរាជធានី ក្រុង និងទីប្រជុំជន។<br>៣-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំត្រួតពិនិត្យចុងក្រោយជាមួយឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមីនា ឆ្នាំ២០១៥ (ត)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១២ | ១២/០៣/១៥<br>ម៉ោង០៩:០០នាទី | ចូលរួមជាសមាជិក ក្នុងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យនិងពិភាក្សាលើ៖<br>១-សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីអនុវត្តការវាយតម្លៃលើផលប៉ះពាល់ នៃលិខិតបទដ្ឋានគតិយុត្ត។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីនគរូបនីយកម្មរាជធានី ក្រុង និងទីប្រជុំជន។<br>៣-បញ្ហាផ្សេងៗ។<br>នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៣ | ១៤/០៣/១៥<br>ម៉ោង១៨:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងព្រឹត្តិការណ៍ដ៏ពិសេសរបស់សភាពាណិជ្ជកម្មបារាំង និងឧស្សាហកម្ម នៅសណ្ឋាគារសូហ្វីតែលភ្នំពេញ។ |
| ១៤ | ១៦/០៣/១៥<br>ម៉ោង០៩:៣០នាទី | ជួបប្រជុំពិភាក្សាការងារអំពីការសាងសង់អគារសារមន្ទីរសព្វទស្សន៍ ជាមួយលោក Kim អ្នកគ្រប់គ្រង ក្រុមហ៊ុន ម៉ាន់ស៊ូដេញ្ជូតិច នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៥ | ១៦/០៣/១៥<br>ម៉ោង១៥:៣០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយតំណាងក្រុមហ៊ុន Union Development Group នៅបន្ទប់ឯកឧត្តម ប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៦ | ១៨/០៣/១៥<br>ម៉ោង១០:០០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយឯកឧត្តម **អេន សំអុល** នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៧ | ១៩/០៣/១៥<br>ម៉ោង០៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់ "បណ្ណជ័យលាភីអាហារូបករណ៍ សម្តេចតេជោ **ហ៊ុនសែន-ហាន់ជា** ចក្ខុវិស័យ១០០ ឆ្នាំ២០១៤" និង "បណ្ណជ័យលាភីអាហារូបករណ៍ សម្តេចតេជោ **ហ៊ុន សែន-ហាន់ជា** ចក្ខុវិស័យ១០០ ឆ្នាំ២០១៤-២០១៨" ជូនដល់និស្សិត នៃសាកលវិទ្យាល័យកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត នៅវិទ្យាស្ថានជាតិអប់រំ ។ |

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមីនា ឆ្នាំ២០១៥ (ត)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១៨ | ២១/០៣/១៥ ម៉ោង១៩:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធហាងសំលៀកបំពាក់អាវធំម៉ាក "Brioni" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅអគារមជ្ឈមណ្ឌលវឌ្ឍនៈ។ |
| ១៩ | ២៣/០៣/១៥ ម៉ោង០៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធសមិទ្ធផលរូបសំណាកព្រះនាងប្រាជ្ញាបារមី ច្រាំងទន្លេសួនច្បារ ជ្រោយចង្វារត្រើយខាងកើត និងសម្ពោធបើកដំណើរការជាផ្លូវការ សណ្ឋាគារស៊ើដង់ សុខាភ្នំពេញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត នៅសណ្ឋាគាររ៉េស៊ីដង់ សុខាភ្នំពេញ។ |
| ២០ | ២៤/០៣/១៥ ម៉ោង០៨:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបើកសន្និបាតអប់រំ យុវជន និងកីឡា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា។ |
| ២១ | ២៥/០៣/១៥ ម៉ោង០៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់សញ្ញាបត្រគ្រូបង្រៀនកម្រិតឧត្តម(បរិញ្ញា+១) ជំនាន់ទី១៩ និងគ្រូ បង្រៀនកម្រិតមូលដ្ឋានឯកទេសភាសាបារាំង-ខ្មែរ ជំនាន់ទី១៦ ព្រមទាំងសម្ពោធអាគារ ០១ខ្នងរបស់ វិទ្យាស្ថានជាតិអប់រំ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត នៅវិទ្យាស្ថានជាតិអប់រំ។ |
| ២២ | ២៦/០៣/១៥ ម៉ោង០៨:៣០នាទី | ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីប្រជុំស្តីពីការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកុម្ភៈ ឆ្នាំ២០១៥ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២៣ | ២៦/០៣/១៥ ម៉ោង១៥:៣០នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មការតាមដាន និងត្រួតពិនិត្យលើការសាងសង់អាកាសយានដ្ឋានអន្តរជាតិ ប្រចាំខែកុម្ភៈ ឆ្នាំ២០១៥ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២៤ | ២៧/០៣/១៥ ម៉ោង០៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់វិហារធំឥស្លាម អាល់សារកាល ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត នៅបឹងកក់ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ |

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមីនា ឆ្នាំ២០១៥ (តចប់)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ២៥ | ២៧/០៣/១៥ ម៉ោង១៦:០០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយ សាស្ត្រាចារ្យគ្រប់គ្រងពាណិជ្ជកម្មនៃសាកលវិទ្យាល័យវ៉ង់ខ្វាង (សាធារណរដ្ឋកូរ៉េ) នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្ដីការគណៈរដ្ឋមន្ត្រី។ |
| ២៦ | ៣០/០៣/១៥ ម៉ោង០៧:៣០នាទី | ចូលរួមជាសមាជិក ក្នុងពិធីបើកកិច្ចប្រជុំបូកសរុបសកម្មភាពក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅទីស្ដីការនាយករដ្ឋមន្ត្រី។ |
| ២៧ | ៣០/០៣/១៥ ម៉ោង១៤:៣០នាទី | ចូលរួមជាសមាជិក ក្នុងពិធីបិទកិច្ចប្រជុំបូកសរុបសកម្មភាពក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅទីស្ដីការនាយករដ្ឋមន្ត្រី។ |
| ២៨ | ៣១/០៣/១៥ ម៉ោង០៨:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបើកសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៤ និងទិសដៅការងារឆ្នាំ២០១៥ របស់ក្រសួងមុខងារសាធារណៈ ក្រោមអធិបតីភាព ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ជាតំណាងដ៏ខ្ពង់ខ្ពស់របស់ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសាលាភូមិន្ទរដ្ឋបាល។ |

# ព្រឹត្តិបត្រព័ត៌មាន



## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌


ទូរស័ព្ទលេខៈ ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខៈ ០២៣ ២១១ ៩៤៣

E-mail: veasna@live.in